# សេចក្តីថ្លែងការណ៍រួម
## ស្តីពី
## “ការប្រឈមរបស់ពលករចំណាកស្រុក ទាក់ទងនឹងក្រុមហ៊ុនជ្រើសរើសពលករ

T& P Co., Ltd និង Giant Ocean International Fishery Co., Ltd ”

សមាគមការពារសិទ្ធិមនុស្ស និងអភិវឌ្ឍន៍ នៅកម្ពុជា ហៅកាត់ថា អាដហុក (ADHOC), អង្គការខារ៉ាមកម្ពុជា (CARAM Cambodia), គណៈកម្មាធិការប្រព្រឹត្តិកម្ម នៃអង្គការ -សមាគមការពារសិទ្ធិមនុស្សកម្ពុជា(CHRAC) និង គណៈកម្មាធិការនៃអង្គការមិនមែនរដ្ឋាភិបាលកម្ពុជា ដើម្បីអនុសញ្ញាលប់បំបាត់រាល់ទម្រង់នៃការរើសអើងលើស្ត្រីភេទ NGO-CEDAW មានការព្រួយបារម្ភយ៉ាងខ្លាំងចំពោះ ការកើនឡើងនូវចំនួនករណីប្រឈមរបស់ពលករចំណាកស្រុក និង ការរំលោភសិទ្ធិការងារ ជាពិសេសចំពោះករណីដែលកើតឡើងថ្មីៗ ទាក់ទងនឹងក្រុមហ៊ុនជ្រើសរើសពលករ T&P Co., Ltd ដែលត្រូវបានដកអាជ្ញាប័ណ្ណដោយក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងក្រុមហ៊ុនជ្រើសរើសពលករ Giant Ocean International Fishery Co., Ltd ដែលបានបិទទ្វារកាលពីដើមឆ្នាំ២០១២ ។

ករណីដែលមិនមានការទទួលខុសត្រូវរបស់ក្រុមហ៊ុនទាំងពីរខាងលើ យើងសង្កេតឃើញថា មានបញ្ហាប្រឈមជាច្រើនចំពោះពលករចំណាកស្រុករួមមាន៖ ការរំលោភបំពាន ការវាយដំ ការបង្ខំឲ្យធ្វើការហួសកម្លាំង ការបាត់ខ្លួន ការបាត់ដំណឹង ការជាប់ពន្ធនាគារនៅប្រទេសទទួល ការមិនបានទទួលប្រាក់ខែ ឬការទទួលប្រាក់ខែដែរតែមិនគ្រប់ចំនួន ការផ្តល់អាហារមិនគ្រប់គ្រាន់អាចបណ្តាលឲ្យធ្លាក់ខ្លួនឈឺធ្ងន់ និង ខ្លះទៀតបានអាចបណ្តាលអោយបាត់បង់ជីវិតជាដើម។ មិនត្រឹមតែប៉ុណ្ណោះ ក្រុមហ៊ុនជ្រើសរើសពលករទាំងនេះបានបញ្ជូនពលករទៅធ្វើការបន្តនៅប្រទេសផ្សេងៗដូចជា៖ ប្រទេសអាហ្វ្រិកខាងត្បូង សឹង្ហបូរី ចិន ហ្វីជី ម៉ូរីទីស និងប្រទេសផ្សេងៗទៀតជាដើម ដែលខុសពីអាជ្ញាប័ណ្ណ ដែលបានអនុញ្ញាតដោយក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ។

យោងតាមប្រព័ន្ធផ្សព្វផ្សាយ និងតាមរបាយការណ៍ស៊ើបអង្កេតរបស់អង្គការ -សមាគម មិនមែនរដ្ឋាភិបាល ដែលធ្វើការងារពាក់ព័ន្ធនឹងពលករចំណាកស្រុក បានបង្ហាញឲ្យឃើញថា មានចំនួនពលកររងគ្រោះសរុបចំនួន១០២នាក់ ដែលក្នុងនោះមានពលកររងគ្រោះដោយសារ ក្រុមហ៊ុន Giant Ocean International Fishery Co., Ltdមានចំនួន៤៦នាក់ និងក្រុមហ៊ុនជ្រើសរើស ពលករ T&P Co., Ltd មានចំនួន ៥៦នាក់ ។ ស្ថិតិខាងលើនេះទទួលបានពីអង្គការ -សមាគម ចំនួន២ គឺអាដហុក និង ខារ៉ាមកម្ពុជា ក្នុងរយៈពេល៦ខែដើមឆ្នាំនេះ។

ក្នុងនាមអង្គការ-សមាគម មិនមែនរដ្ឋាភិបាល សូមអំពាវនាវដល់ស្ថាប័នពាក់ព័ន្ធ និង ស្ថាប័នតុលាការ ជំរុញឲ្យមានការទទួលខុសត្រូវ ដោះស្រាយបញ្ហាខាងលើ និងអនុវត្តទៅតាម នីតិវិធីដែលមានចែងក្នុងច្បាប់ជាធរមាន ដែលទាក់ទងនឹងក្រុមហ៊ុន Giant Ocean International Fishery Co., Ltd និង T&P Co., Ltd ឲ្យបានទាន់ពេលវេលា ។

យើងជាអង្គការ-សមាគមមិនមែនរដ្ឋាភិបាល សូមកោតសរសើរ និង ថ្លែងអំណរគុណ ចំពោះរាជរដ្ឋាភិបាល ដែលបានចាត់វិធានការតាមផ្លូវច្បាប់ទៅលើក្រុមហ៊ុនមួយចំនួន ដែលមិន បានអនុវត្តតាមគោលការណ៍ច្បាប់ជាធរមាន ។ ទន្ទឹមនឹងនេះ ដើម្បីលើកកម្ពស់ និងការពារសិទ្ធិ ពលករចំណាកស្រុក យើងខ្ញុំសូមអំពាវនាវយ៉ាងទទូចដល់រាជរដ្ឋាភិបាល និងស្ថាប័នពាក់ព័ន្ធ លោកមេត្តាចាត់វិធានការជាបន្ទាន់ដូចខាងក្រោម៖

១. ស្នើក្រសួងការងារនិង បណ្តុះបណ្តាលវិជ្ជាជីវៈ ព្រមទាំងស្ថាប័នពាក់ព័ន្ធជួយដោះ ស្រាយសំណងជូនពលករចំណាកស្រុកដែលទទួលរងនូវការរំលោភបំពាន និងការកេង ប្រវ័ញ្ចទាក់ទងនឹងក្រុមហ៊ុនទាំងពីរដោយអនុលោមតាមអនុក្រិត្យលេខ១៩០ ចុះថ្ងៃទី ១៧ ខែសីហា ឆ្នាំ ២០១១ ។

២. ស្នើ ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រសួងមហាផ្ទៃ ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ បង្កើត និង បង្កើនឲ្យមានប្រសិទ្ធភាពនូវប្រព័ន្ធឆ្លើយតប ជាបន្ទាន់ សម្រាប់ជួយសម្រួលដល់ទំនាក់ទំនងរវាងពលករ និងក្រុមគ្រួសារ ដែលកំពុង រងគ្រោះនៅប្រទេសទទួលក្នុងការជួយធ្វើមាតុភូមិនិវត្តន៍ ព្រមទាំង បង្កើតឲ្យមានយន្តការ ជាក់លាក់ដើម្បីដោះស្រាយបញ្ហាប្រឈម របស់ពលករចំណាកស្រុកដែលកំពុងស្ថិតក្នុង ស្ថានភាពលំបាក ជាពិសេសខណៈដែលក្រុមហ៊ុនមួយចំនួនបិទទ្វារ ឬដកអាជ្ញាប័ណ្ណ ។

៣.ស្នើ ក្រសួងមហាផ្ទៃ ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ក្រសួង

*យុត្តិធម៌  និង ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ពង្រឹងការអនុវត្តន៍ច្បាប់ប្រកបដោយប្រសិទ្ធភាព ជាពិសេសស្ថាប័នតុលាការ ចាត់វិធានការផ្តន្ទាទោស ចំពោះជនប្រព្រឹត្តល្មើស ដើម្បីជួយទប់ស្កាត់ការជួញដូរមនុស្ស និងការរំលោភបំពានសិទ្ធិពលករចំណាក ស្រុក ។*

*៤.សូមឲ្យរាជរដ្ឋាភិបាលផ្តល់សច្ចាប័នលើអនុសញ្ញាILO ១៨៩ ស្តីពី ការងារសមរម្យសម្រាប់អ្នកបម្រើការងារតាមផ្ទះ ។*

*ភ្នំពេញ ថ្ងៃទី ១៤ សីហា ឆ្នាំ ២០១២*

***ព័ត៌មានបន្ថែមសូមទំនាក់ទំនង៖***

*-លោក ស្រី វេជ្ជបណ្ឌិត **ពុង ឈីវកេក** ប្រធានបណ្តាញ* NGO CEDAW *០១២ ៨០២៥០៦*

*-លោក **យ៉ា ណាវុធ** នាយកប្រតិបត្តិ នៃអង្គការខារ៉ាម ០១២ ៩៦១ ៤២៧*

*-លោកស្រី ជួន ចំរុង ប្រធានកម្មវិធីស្ត្រី និងកុមារ នៃសមាគមអាដហុក*

*០១២ ៨៣២ ០៦៩*

*-លោក **សួន ប៊ុនស័ក្តិ** ប្រធានលេខាធិការដ្ឋានគណៈកម្មាធិការប្រព្រឹត្តិកម្ម*

*០៩២ ៣៤៤ ៣៥៧*